ព្រះរាជាណាចក្រកម្ពុជា

**គណៈរដ្ឋមន្ត្រី** ជាតិ សាសនា ព្រះមហាក្សត្រ

**លេខាធិការដ្ឋានមុខងារសាធារណៈ**

លេខ: ៤០១ មស.នក

# ប្រកាស
# ស្តីពី
# ការកែសម្រួលសមាសភាពនៃគណៈកម្មាធិការ
# សម្រុះសម្រួលពាក់ព័ន្ធ នឹងកិច្ចការមុខងារសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ សរ ៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកប/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០១/០៥៦ ស្តីពីការតែងតាំងឯកឧត្តម **ប្រាជ្ញ ចន្ទ** ជាអភិបាលខេត្តបាត់ដំបង
- យោងតាមការចាំបាច់។

សហការរៀបចំដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (GIZ)-ចម្លងខ្លឹមសារទាំងស្រុងតាមច្បាប់ដើម

# សម្រេច

**ប្រការ ១.-**

កែសម្រួលសមាជិកពេញសិទ្ធិ និងបំពេញបន្ថែមសមាជិកបម្រុង នៃគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១. ឯកឧត្តម | **ពេជ្រ ប៊ុនធិន** | ជាប្រធាន |
| ២. ឯកឧត្តម | **ប៉ាន់ សួរស័ក្តិ** | ជាអនុប្រធាន |
| ៣. ឯកឧត្តម | **ប៊ុន សុខ** | ជាសមាជិក |
| ៤. ឯកឧត្តម | **សយ ស៊ីផុន** | ជាសមាជិក |
| ៥. ឯកឧត្តម | **សក់ សេដ្ឋា** | ជាសមាជិក |
| ៦. ឯកឧត្តម | **មោក សុធារិន** | ជាសមាជិក |
| ៧. ឯកឧត្តម | **ជួប សុផាន** | ជាលេខាធិការ |

**សមាជិកបំរុង**

| | | |
|---|---|---|
| ១. ឯកឧត្តម | **ឆយ អូន** | ជាសមាជិកបំរុង |
| ២. ឯកឧត្តម | **ឌុច សុន** | ជាសមាជិកបំរុង |
| ៣. ឯកឧត្តម | **សៀង កែវឡាយ** | ជាសមាជិកបំរុង |
| ៤. ឯកឧត្តម | **អៀម យ៉ាង** | ជាសមាជិកបំរុង |
| ៥. ឯកឧត្តម | **គុយ សារ៉ុធ** | ជាសមាជិកបំរុង |
| ៦. លោក | **អ៊ឹង សុផុន** | ជាលេខាធិការបំរុង |

**ប្រការ ២.-**

ប្រកាសលេខ ៦៨៨ មស.នក ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសមាសភាពគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធ នឹងកិច្ចការមុខងារសាធារណៈ ត្រូវជំនួសដោយបច្ចុប្បន្នប្រកាសនេះ។

**ប្រការ ៣.-**

អគ្គនាយកដ្ឋានមុខងារសាធារណៈ អគ្គាធិការដ្ឋាន នាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច ខុទ្ទកាល័យ និង ឯកឧត្តម អស់លោកដែលមានឈ្មោះក្នុងប្រការ ១ មានភារកិច្ចអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០១

**ប្រធាន**

**ពេជ្រ ប៊ុនធិន**

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- គ្រប់ក្រសួង ស្ថាប័ន
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ